# ភាយនិព្ពិន្ទជាតក



ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធបុរសម្នាក់ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **ផុដ្ឋស្ស មេ** ដូច្នេះជាដើម ។

បានឮថា បុរសម្នាក់ក្នុងក្រុងសាវត្ថី ត្រូវនឿយនាយដោយរោគលឿង (គឺរោគឃ្វង់) ត្រូវហាមដោយទោស ។ កូននិងប្រពន្ធរបស់គាត់គិតថា តើអ្នកណាអាចនឹងមើលថែគាត់បាន ។ បុរសនោះគិតថា ប្រសិនបើយើងបានជាសះស្បើយចាករោគនេះ យើងនឹងបួស ។ កន្លងទៅបានពីរបីថ្ងៃ បុរសនោះក៏បានសេចក្តីសប្បាយតិចតួច ហើយជាអ្នកមិនមានរោគ គាត់ទៅវត្តជេតពន ទូលសូមបព្វជ្ជានឹងព្រះសាស្តា ។ បុរសនោះបានបព្វជ្ជា និងឧបសម្បទាក្នុងសម្នាក់ព្រះសាស្តា មិនយូរប៉ុន្មាន លោកក៏បានសម្រេចព្រះអរហត្ត ។

ថ្ងៃមួយ ភិក្ខុទាំងឡាយញ៉ាំងកថាឲ្យតាំងឡើងក្នុងធម្មសភាថា ម្នាលអាវុសោ បុរសឈ្មោះនោះ មានរោគលឿង ហើយគិតថា បើយើងជាពីរោគនេះនឹងបួស ដូច្នេះគេក៏បានបួស និងបានសម្រេចព្រះអរហត្ត ។ ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ

អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នារឿងអ្វី ? កាលពួកភិក្ខុទូលថា ដោយរឿងឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែកាលឥឡូវនេះទេ ក្នុងកាលមុន សូម្បីបណ្ឌិតទាំងឡាយក៏បានពោលយ៉ាងនេះ កាលជាចាករោគហើយ ក៏បួស ធ្វើសេចក្តីចម្រើនដូចគ្នាដែរ ដូច្នេះហើយ ព្រះអង្គនាំអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ កាលចម្រើនវ័យហើយ លោករៀបចំទុកដាក់ទ្រព្យសម្បត្តិ ហើយរស់នៅ (បន្ទាប់មក) លោកមានរោគលឿង ។ សូម្បីពេទ្យទាំងឡាយក៏មិនអាចនឹងថែទាំបាន សូម្បីកូននិងប្រពន្ធក៏មានវិប្បដិសារី ។ ព្រះពោធិសត្វគិតថា បើយើងជាពីរោគនេះ យើងនឹងបួស ដូច្នេះហើយ កាលបានសេចក្តីសុខសប្បាយតិចតួច (បន្ទាប់មក) ក៏ជាសះស្បើយ ជាមនុស្សមិនមានរោគ លោកចូលទៅកាន់ព្រៃហិមពាន្ត បួសជាឥសី បានមស្រេចអភិញ្ញា និងសមាបត្តិ រស់នៅដោយឈានសុខ ហើយគិតថា អស់កាលមានប្រមាណប៉ុណ្ណេះឈ្មោះថា សេចក្តីសុខបែបនេះ យើងមិនដែលបានឡើយ ដូច្នេះកាលនឹងបន្លឺឧទាន ទើបពោលគាថាទាំងនេះថា

ផុដ្ឋស្ស មេ អញ្ញតរេន ព្យាធិនា, រោគេន ពាឡ្ហំ ទុខិតស្ស រុប្បតោ;
បរិសុស្សតិ ខិប្បមិទំ កឡេវរំ, បុប្ផំ យថា បំសុនិ អាតបេ គតំ។

កាលអញត្រូវព្យាធិ រោគណាមួយប៉ះពាល់ហើយ ដល់នូវសេចក្តីទុក្ខយ៉ាងខ្លាំងក្លា ដែលរោគកំពុងបៀតបៀន រាងកាយនេះក៏នឹងរីងស្ងួតយ៉ាងឆាប់ ដូចជាផ្កាឈើដែលគេដោតលើអាចម៍ដី ដ៏ក្តៅ ( ក៏ស្ងួតដូច្នោះ ) ។

អជញ្ញំ ជញ្ញសង្ខាតំ, អសុចិំ សុចិសម្មតំ;
នានាកុណបបរិបូរំ, ជញ្ញរូបំ អបស្សតោ។

*(រាងកាយនេះ) មិនជាទីគាប់ចិត្ត តែជនពាលពោលថាជាទីគាប់ចិត្ត មិនស្អាតទេ តែជនពាល សន្មតថាជារបស់ស្អាត រាងកាយដ៏ពេញប្រៀបដោយសាកសពផ្សេង ៗ មានសភាពជាទីគាប់ចិត្តនៃជនពាល ។*

ធិរត្ថុមំ អាតុរំ បូតិកាយំ, ជេគុច្ឆិយំ អស្សុចឹ ព្យាធិធម្មំ;
យត្ថប្បមត្តា អធិមុច្ឆិតា បជា, ហាបេន្តិ មគ្គំ សុគតូបបត្តិយា។

*យើងគួរតិះដៀលនូវកាយស្អុយនេះ ជារបស់ឈឺជានិច្ច គួរខ្ពើមរអើម មិនស្អាត មានព្យាធិជាធម្មតា ដែលពួកសត្វប្រមាទ ជ្រប់ជាប់ ញាំងផ្លូវនៃសុគតិភព ឲ្យវិនាសសាបសូន្យ ។*

*បណ្ដាបទទាំងនោះ បទថា* **អញ្ញតរេន** *សេចក្ដីថា ត្រូវព្យាធិ គឺ បណ្ដុពោគ (ពោគលឿង) មួយ ក្នុងបណ្ដាពោគទាំង ៩៨ ប្រភេទ ។*

*ព្រះមហាសត្វកាលពិចារណាភាពមិនស្អាត និងភាពរសាប់រសល់ឈឺជានិច្ច ដោយប្រការផ្សេងៗហើយ នឿយនាយនឹងរូបកាយ ចម្រើនព្រហ្មវិហារទាំង ៤ ដរាបអស់ជីវិត ហើយបានទៅកាន់ព្រហ្មលោក ។*

*ព្រះសាស្ដានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈ និងប្រជុំជាតក ក្នុងកាលបញ្ចប់នៃសច្ចៈ ជនជាច្រើនបានសម្រេចសោតាបត្តិផលជាដើម ។*

**តទា តាបសោ អហមេវ អហោសឹ** *តាបសក្នុងកាលនោះ គឺតថាគតនេះឯង ។*

*កាយនិព្ពិន្ទជាតក ចប់ ។*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តិកនិបាត កុម្ភវគ្គ បិដកលេខ ៥៨ ទំព័រទី ១៧៧)*

*ថ្ងៃ សុក្រ ១៤ រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ១០ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ*